**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

# សារលិខិតអបអរសាទរ

**សូមក្រាបបង្គំទូលថ្វាយ**

**សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី នន្ទ ង៉ែត សម្តេចព្រះមហាសង្ឃរាជ**

**នៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត !**

ខ្ញុំព្រះករុណាខ្ញុំ និងភរិយា ពិតជាមានសេចក្តីបីតិសោមនស្សរីករាយក្រៃលែង សូមសម្តែងនូវអំណរសាទរ ប្រកបដោយមនោសញ្ចេតនាជ្រាលជ្រៅបំផុត ប្រគេនចំពោះ **សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ក្នុងឱកាសដែល**សម្តេច** ត្រូវបាន **ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ប្រោសព្រះរាជទានត្រាស់បង្គាប់ ដំឡើង និងតែងតាំងព្រះឋានៈជា **សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា**។

ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ **សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី** បានចូលរួមចំណែក និងបានខិតខំប្រឹងប្រែងរួមគ្នាជាមួយរាជរដ្ឋាភិបាល ក្នុងបុព្វហេតុកសាង និងលើកស្ទួយវិស័យព្រះពុទ្ធសាសនាឡើងវិញឱ្យបានរីកចម្រើនរហូតមកដល់បច្ចុប្បន្ន ដែលវិស័យនេះត្រូវបានបំផ្លិចបំផ្លាញទាំងស្រុង ក្នុងរបបប្រល័យពូជសាសន៍ប៉ុលពត។ **សម្តេច** បានលះបង់បូជាព្រះកាយពល និងព្រះបញ្ញាញាណដោយមិនខ្លាចនឿយហត់ ក្នុងបុព្វហេតុដ៏ថ្លៃថ្លា ជាពិសេសក្នុងការលើកស្ទួយវិស័យព្រះពុទ្ធសាសនាឡើងវិញ ដែលជាសាសនារបស់ជាតិ សម្រាប់ជាឧត្តមប្រយោជន៍ដ៏ធំធេងជូនជាតិ ក្រោមបាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ**។

នៅក្នុងឱកាសដ៏នក្ខត្តឫក្សវិសេសវិសាលថ្លៃថ្លានេះ ខ្ញុំព្រះករុណាខ្ញុំ និងភរិយា សូមលើកហត្ថបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតាថែរក្សាព្រះរាជាណាចក្រកម្ពុជា ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ សូមយាងអភិបាលបីបាច់ថែរក្សា និងប្រោះព្រំនូវសព្ទសាធុការពរ ប្រគេនចំពោះ **សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** សូមមានព្រះសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា វាងវៃ ព្រះជន្មាយុយឺនយូរ និងសមប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា** ព្រះមេត្តាទទួលនូវអភិវន្ទនកិច្ចជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ពីខ្ញុំព្រះករុណាខ្ញុំ និងភរិយា។

ថ្ងៃចន្ទ ៩កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៤

**នាយឧត្តមសេនីយ៍ ទៀ សីហា**